ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ
លេខ: ១៨៣/...សជ

# របាយការណ៍បូកសរុបសកម្មភាព
# និងលទ្ធផលការងារបង្ការ-ទប់ស្កាត់ និងបង្ក្រាបអំពើជួញដូរមនុស្ស
# និងអំពើធ្វើអាជីវកម្មផ្លូវភេទ ប្រចាំខែតុលា និងទិសដៅខែវិច្ឆិកា ឆ្នាំ ២០១៦

( គិតចាប់ពីថ្ងៃទី ២៦ ខែកញ្ញា ឆ្នាំ២០១៦ ដល់ថ្ងៃទី ២៥ ខែតុលា ឆ្នាំ២០១៦ )

## I.ស្ថានភាពទូទៅ

នៅក្នុងខែតុលា ឆ្នាំ២០១៦ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) បានបំពេញតួនាទីតាមមុខងាររបស់ខ្លួនដែលមានចែងក្នុងព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្តីសម្រេច និងប្រកាស ដោយមានកិច្ចសហប្រតិបត្តិការរួមគ្នាជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ទាំងថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងអន្តរជាតិ រួមទាំងអង្គការមិនមែនរដ្ឋាភិបាលជាដៃគូជាតិនិងអន្តរជាតិ។

អំពីសភាពការណ៍បទល្មើសជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដោយផ្អែកតាមរបាយការណ៍ដែលគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ទទួលបានពីក្រសួង ស្ថាប័នពាក់ព័ន្ធ លេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ថ្នាក់ក្រោមជាតិ បានរកឃើញបទល្មើសជាច្រើនករណី តាមទម្រង់ផ្សេងៗដូចជា ការធ្វើអាជីវកម្មផ្លូវភេទ សញ្ញារកម្ម និងទេសន្តប្រវេសន៍ស្វែងរកការងារ ការស្វែងរកគូស្រករនៅក្រៅប្រទេស ។ ក្នុងចំណោមជនទេសន្តប្រវេសន៍ ដែលកំពុងនៅក្រៅប្រទេស ទាំងស្របច្បាប់ និងមិនស្របច្បាប់ ត្រូវបានរងគ្រោះជាបន្តបន្ទាប់ និងត្រូវបានបញ្ជូនមកកម្ពុជាវិញ ហើយមួយចំនួនបានត្រឡប់មកផ្ទះវិញដោយខ្លួនឯង និងខ្លះទៀតបាត់ដំណឹង ។ កត្តាទាំងអស់នេះ ជាបញ្ហាប្រឈម ដែលគណៈកម្មាធិការជាតិ គ.ជ.ប.ជ ត្រូវរួមសហការជាមួយបណ្តាក្រសួង ស្ថាប័ន ដែលជាសមាជិក និង អង្គភាពដែលពាក់ព័ន្ធព្យាយាមបង្ការទប់ស្កាត់ និងដោះស្រាយបញ្ហារួមគ្នា ។

អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ បានពង្រឹងកិច្ចសហប្រតិបត្តិការជាមួយដៃគូជាតិ និងអន្តរជាតិពាក់ព័ន្ធក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងជំរុញការសម្របសម្រួល ជាមួយក្រុមការងារ អន្តរក្រសួង ស្ថាប័ន ព្រមទាំងរាជធានី-ខេត្ត ដើម្បីរកដំណោះស្រាយបញ្ហាប្រឈមនានា សុំឲ្យមានការស្រាវជ្រាវស៊ើបអង្កេតបទល្មើស និងសិក្សាពីផលប៉ះពាល់នៃអំពើជួញដូរមនុស្ស ។

អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានបំពេញតួនាទី និងភារកិច្ចយ៉ាងមមាញឹក ខិតខំប្រឹងប្រែងបន្តអនុវត្តយុទ្ធវិធីស្របតាមផែនការសកម្មភាពជាតិ ឆ្នាំ២០១៤-២០១៨ ក្នុងគោលបំណងលើកកម្ពស់ប្រសិទ្ធភាពក្នុងការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត និងជំរុញការដឹកនាំ ស្តីពីការបង្ការ បង្ក្រាបអំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មផ្លូវភេទ និងការដាក់ទណ្ឌកម្ម លើជនល្មើស ។

របាយការណ៍ខាងក្រោម ជាទិន្នន័យដែលទទួលបានពីក្រុមការងារការពារជនរងគ្រោះដឹកនាំដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាចំនួន០១ច្បាប់ ,ក្រុមការងារអនុវត្តន៍ច្បាប់ចំនួន០១ច្បាប់ ដែលដឹកនាំដោយអគ្គស្នងការដ្ឋាននគរបាលជាតិ និងខេត្ត ចំនួន១៦ច្បាប់ គឺ ខេត្ត កោះកុង ,ព្រះសីហនុ ,តាកែវ ,កំពង់ស្ពឺ ,កណ្តាល ,ព្រៃវែង ប៉ៃលិន បាត់ដំបង ,បន្ទាយមានជ័យ, ព្រះវិហារ ,កំពង់ធំ ,ក្រចេះ ,ស្ទឹងត្រែង ,រតនគិរី ,មណ្ឌលគិរី ,កំពង់ចាម និងសកម្មភាពរបស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ដែលទទួលបានលទ្ធផលដូចខាងក្រោម ៖

## II.លទ្ធផលការងារ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

នៅក្នុងខែតុលា ឆ្នាំ២០១៦ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) និងគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ក្រោមជាតិ បានបន្តយកចិត្តទុកដាក់អនុវត្តផែនការសកម្មភាព និងទិសដៅការកិច្ចរបស់ខ្លួន ដោយពង្រឹងកិច្ចសហប្រតិបត្តិការ រវាងបណ្តាក្រសួង ស្ថាប័ន មន្ទីរ អង្គភាពពាក់ព័ន្ធ និងអង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ បានធ្វើឲ្យសម្រេចនូវលទ្ធផលដូចខាងក្រោម ៖

### ក. ការអនុវត្តយុទ្ធសាស្ត្រប្រឆាំងការជួញដូរមនុស្ស

១. ការងារបង្ការ-ទប់ស្កាត់:

១.១.ការផ្សព្វផ្សាយ អប់រំ

នៅក្នុងខែតុលា ឆ្នាំ២០១៦នេះ ការផ្សព្វផ្សាយទាំងនៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ ស្ថាប័នពាក់ព័ន្ធអាជ្ញាធរ និងសមត្ថកិច្ច បានសហការជាមួយអង្គការដៃគូ ធ្វើការផ្សព្វផ្សាយជាសាធារណៈ ទៅតាមគោលដៅចំនួន៩៨៤លើក បើប្រៀបធៀបខែមុនមានចំនួន១,៦២៥លើក មានការថយចុះចំនួន៦៤១លើក ស្មើនឹង៣៩.៤៤% និងមានមនុស្សចូលរួមសរុបចំនួន៨៦,០៨២នាក់ បើប្រៀបធៀបខែមុនមានចំនួន១៩២,៧៣០នាក់ មានការកើនឡើងចំនួន១០៦,៤៨៦នាក់ ស្មើនឹង៥៥.៣៣% ក្នុងនោះស្ត្រីមានចំនួន៤៤,៩០៨នាក់។ (ឧបសម្ព័ន្ធទី១)

១.២.ការងារបង្ការ-ទប់ស្កាត់

យោងលើលទ្ធផលសម្រេចបាន លើការងារបង្ការ-ទប់ស្កាត់អំពើជួញដូរមនុស្ស ដែលនាយកដ្ឋានជំនាញសមត្ថកិច្ចកងរាជអាវុធហត្ថ និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត សហការជាមួយស្ថាប័នពាក់ព័ន្ធទទួលបានលទ្ធផលដូចខាងក្រោម៖

- ផ្សព្វផ្សាយ និងការឃ្លាំមើលចំនួន៤៣លើកបើប្រៀបធៀបខែមុនមានចំនួន១៨លើក កើនឡើងចំនួន២៥លើក ស្មើនឹង១៣៨.៨៨% មានមនុស្សសរុបចំនួន២២៤នាក់ បើប្រៀបធៀបខែមុនមានចំនួន១៧៣នាក់ មានការកើនឡើងចំនួន៥១នាក់ ស្មើនឹង២៩.៤៧% ស្ត្រីចំនួន១១២នាក់ ។
  - ស្នងការដ្ឋាននគរបាលខេត្តសៀមរាប ,កំពង់ធំ ,ស្វាយរៀង ,ព្រៃវែង ,និងខេត្តមណ្ឌលគិរី បានល្បាតឃ្លាំមើលគោលដៅសង្ស័យមានសកម្មភាពអាជីវកម្មផ្លូវភេទ បានចំនួន៣៩លើក (ខេត្ត សៀមរាប១២លើក ,កំពង់ធំ១២លើក,ស្វាយរៀង០៨លើក ,ព្រៃវែង០២លើក ,និងខេត្តមណ្ឌលគិរី០៥លើក) ។
  - ស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យ កម្លាំងនគរបាលជំនាញ បានសហការជាមួយកម្លាំងអធិការដ្ឋាននគរបាលស្រុកថ្មពួក ,ស្រុកម៉ាឡៃ(ប៉ុស្តិ៍បឹងបេង) ,អធិការដ្ឋាននគរបាលស្រុកអូរជ្រៅ(ប៉ុស្តិ៍អូរពាជាន់) និងកម្លាំងវរៈសេនាតូចការពារព្រំដែនគោក ៩១១ បានធ្វើការទប់ស្កាត់ និងហាមឃាត់ពលរដ្ឋដែលបានធ្វើចំណាកស្រុកខុសច្បាប់នៅតាមបន្ទាត់ព្រំដែនកម្ពុជាថៃ ដើម្បីទៅរកការងារធ្វើនៅប្រទេសថៃ បានចំនួន០៤លើក មានពលករសរុបចំនួន២២៤នាក់ ស្រីចំនួន១១២នាក់ ក្នុងនោះខេត្តៈ(សៀមរាប៩២នាក់ ស្រី៤៥នាក់) ,កំពង់ធំ៦២នាក់ ស្រី២២នាក់),បាត់ដំបង០២នាក់ ស្រី០១នាក់ និងខេត្តបន្ទាយមានជ័យ៦៨នាក់ ស្រី៤៤នាក់ ។
- តាមដាននិងឃ្លាំមើលបានចំនួន ៥០៤គោលដៅ បើប្រៀបធៀបខែមុនចំនួនគោលដៅមាន៥១៨គោលដៅ មានការថយចុះ១៤គោលដៅ ស្មើនឹង២.៧០% មានមនុស្សចំនួន៤,២១៥នាក់ បើប្រៀបធៀបខែមុនមានចំនួន២,០២៣នាក់ មានការកើនឡើងចំនួន២,១៩២ ស្មើនឹង១០៨.៣៥% ស្ត្រីចំនួន៣,០៨៩នាក់ ។
  - ស្នងការដ្ឋាននគរបាលខេត្តតាកែវ ,ពោធិ៍សាត់ ,ព្រះវិហារ ,សៀមរាប និងខេត្តមណ្ឌលគិរី បានធ្វើបច្ចុប្បន្នភាពទិន្នន័យស្ថិតិ និងធ្វើកិច្ចសន្យាហាមឃាត់ ការប្រព្រឹត្តអំពើសញ្ចារកម្ម និងផ្សព្វផ្សាយច្បាប់ ស្តីពីការ បង្ក្រាប អំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដល់ម្ចាស់អាជីវកម្ម ស្ត្រីបម្រើការងារក្នុងហាងម៉ាស្សា, ខារ៉ាអូខេ បានចំនួន៤៧៩គោលដៅ និងមានមនុស្សចំនួន៣,៥៨៦នាក់ (ស្រីចំនួន៣,០៨៩នាក់) ។

- បច្ចុប្បន្នភាពទិន្នន័យគោលដៅសង្ស័យប្រព្រឹត្តបទល្មើសជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ រាជធានី-ខេត្ត មានចំនួន ៧១គោលដៅ ក្នុងនោះអំពើជួញដូរមនុស្សចំនួន០៥គោលដៅ និងអំពើធ្វើអាជីវកម្មផ្លូវភេទចំនួន៦៦ គោលដៅ ។

○ក្រុមការងារលេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្តព្រះសីហនុ(យោងតាមរបាយការណ៍គណៈកម្មាធិការ គ.ខ.ប.ជ ខេត្ត) បានសហការជាមួយអង្គការម្លប់តាប៉ាង ដើម្បីក្សាសុវត្ថិភាពកុមារបានដាក់បណ្តាញម៉ូតូឌុប និងម៉ូតូកង់បីចំនួន១៤៣ នាក់ផ្ទះសំណាក់,សណ្ឋាគារចំនួន២៥កន្លែង អ្នកលក់តាមឆ្នេរសមុទ្រចំនួន៨៤នាក់ បណ្តាញតាមសហគមន៍ចំនួន ៦០នាក់ ភ្នាក់ងារទេសចរណ៍ចំនួន០២នាក់ និងសមាជិកបណ្តាញជាបុគ្គលិកផ្ទះសំណាក់ ,សណ្ឋាគារមានចំនួន ៣៤២ នាក់ ។

**២. ការងារការពារ ស្តារនីតិសម្បទាសមាហរណកម្ម និងមាតុភូមិនិវត្តន៍**

**២.១ ការងារការពារ-ស្តារនីតិសម្បទាជនរងគ្រោះ**

គណៈកម្មាធិការខេត្តប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ខ.ប.ជ) បានសហការជាមួយអង្គការដៃគូចុះជួយដល់ជនរងគ្រោះ និងជនងាយរងគ្រោះដោយអំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ និងការកេងប្រវ័ញ្ចកម្លាំងពលកម្ម សរុបបានចំនួន៤១នាក់ បើប្រៀបធៀបខែមុនមានចំនួន១៤៣នាក់ មានការថយចុះចំនួន១០២នាក់ ស្មើនឹង៧១.៣២% ក្នុងនោះ ស្ត្រីមានចំនួន១១នាក់ ។

+**មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្តបន្ទាយមានជ័យ** បានធ្វើកិច្ចសហការជាមួយប្រទេសថៃ ជួយជនរងគ្រោះដោយអំពើជួញដូរមនុស្សបញ្ជូនឲ្យស្នាក់នៅរយៈពេលខ្លីនៅមជ្ឈមណ្ឌលស្តារនីតិសម្បទាសរុបចំនួន ២០នាក់ ក្នុងនោះ(ស្រី០៥នាក់ ,បុរស០៣នាក់ ,កុមារា០៩នាក់,កុមារី០៣នាក់ ) ក្នុងចំណោមជនរងគ្រោះទាំង ២០នាក់ មជ្ឈមណ្ឌលបានបញ្ជូនទៅអង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ ។

+**មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្តក្រចេះ** មន្ទីរបានសហការជាមួយអង្គការមជ្ឈមណ្ឌលកម្ពុជា ដើម្បីការពារសិទ្ធិកុមារ CCPCR ធ្វើសមាហរណកម្មជនរងគ្រោះ មកពីប្រទេសម៉ាឡេស៊ីចំនួន២១នាក់ ឲ្យរស់នៅ ក្នុងសហគមន៍ វិញ ក្នុងនោះស្រុកឆ្លូងមានចំនួន ១៨នាក់ ស្រីចំនួន ០៣នាក់ ស្រុកព្រែកប្រសព្វចំនួន០៣នាក់ ។

**២.២ សមាហរណកម្ម និងមាតុភូមិនិវត្តន៍ៈ ក្នុងខែតុលា ឆ្នាំ ២០១៦**

ស្នងការដ្ឋាននគរបាលរាជធានី/ខេត្ត បានទទួល និងសម្ភាសពលករទេសន្តប្រវេសន៍ ដែលអាជ្ញាធរម៉ាឡេស៊ីបញ្ជូនមក និងអាជ្ញាធរចិន បញ្ជូនមកវិញក្នុងខែតុលា ឆ្នាំ២០១៦ ក្រោយធ្វើការសម្ភាសរួចពលរដ្ឋខ្មែរទាំងអស់ត្រូវបានអប់រំណែនាំឲ្យត្រឡប់ទៅលំនៅដ្ឋានវិញ ព្រមទាំងបានសម្ភាសពលករ ពលការិនីរងគ្រោះ ចំនួន១០នាក់ ស្រីចំនួន០៧នាក់ ក្នុងនោះមាន ៖

-ទៅដោយខ្លួនឯងចំនួន០៥នាក់ ស្រីចំនួន០២នាក់ មកពីប្រទេសឥណ្ឌូនេស៊ី០៣នាក់ និងប្រទេសចិន០២នាក់។

-មកពីប្រទេសចិនចំនួន០៥នាក់(ទៅតាមរយៈមេខ្យល់) ។

**២.៣ ការងារទទួលពលករខ្មែរពីអាជ្ញាធរបរទេសៈ**

ស្នងការដ្ឋាននគរបាលខេត្ត បន្ទាយមានជ័យ ,បាត់ដំបង និងខេត្តស្វាយរៀង បានទទួលការសម្ភាសពលរដ្ឋខ្មែរ ដែលអាជ្ញាធរថៃ បញ្ជូនមកវិញតាមច្រកទ្វារអន្តរជាតិប៉ោយប៉ែត ច្រកទ្វារអន្តរជាតិដូង ច្រកទ្វារភ្នំដី(គីឡូម៉ែត១៣) និងច្រកទ្វារអន្តរជាតិបាវិត មានចំនួន៤,៩០៦នាក់(ស្រីចំនួន១,៦១៣នាក់) អនីតិជនចំនួន៤៤៥នាក់ (ស្រីចំនួន១៩៧នាក់) ។

- ស្នងការដ្ឋាននគរបាលខេត្ត បន្ទាយមានជ័យមានចំនួន៤,៥៥៦នាក់ (ស្រីមានចំនួន១,៥០១នាក់) អនីតិជនចំនួន៤២០នាក់ (ស្រីចំនួន១៩៧នាក់) ។
- ស្នងការដ្ឋាននគរបាលខេត្ត បាត់ដំបងមានចំនួន៣៥០នាក់(ស្រីមានចំនួន១១២នាក់)អនីតិជនចំនួន២៥នាក់។
- ស្នងការដ្ឋាននគរបាលខេត្ត ស្វាយរៀង មានចំនួន០៩នាក់ (ស្រីមានចំនួន០៧នាក់) អនីតិជនចំនួន០៨នាក់ (ស្រីចំនួន០៦នាក់) ។

-មានប្រជាពលរដ្ឋខ្មែរចំនួន២៧៨នាក់ ត្រូវអាជ្ញាធរថៃឃាត់ខ្លួនលើសពីរយៈពេល១ខែ មុនបញ្ជូនមកកម្ពុជាវិញ ក្រោយធ្វើការសម្ភាសរួច ពលរដ្ឋខ្មែរទាំងអស់ត្រូវបានអប់រំណែនាំឲ្យត្រឡប់ទៅលំនៅដ្ឋានវិញ ។

**៣. ការងារអនុវត្តច្បាប់**

-កិច្ចប្រតិបត្តិការបង្ក្រាបបទល្មើស

នាយកដ្ឋានជំនាញ និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត ព្រមទាំងកងរាជអាវុធហត្ថលើផ្ទៃប្រទេស បានខិតខំតាមដានស្រាវជ្រាវបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទបានចំនួន១០ករណី/14ករណី(បើប្រៀបធៀប ខែមុនថយចុះចំនួន០៤ករណី) ឃាត់ខ្លួនជនសង្ស័យបញ្ជូនទៅសាលាដំបូងបានចំនួន១២នាក់ ជនបរទេសចំនួន០១នាក់ (សញ្ជាតិកូរ៉េ០១នាក់) សង្គ្រោះជនរងគ្រោះបានចំនួន៣៤នាក់ ក្នុងនោះអាយុក្រោម១៥ឆ្នាំចំនួន១១នាក់ អាយុពី១៥-១៧ឆ្នាំចំនួន០៨នាក់ និងអាយុ១៨ឆ្នាំឡើងចំនួន១៥នាក់ (ប្រគល់ឲ្យមន្ទីរសង្គមកិច្ចចំនួន០៨នាក់ និង២៦នាក់ទៀតប្រគល់ឲ្យគ្រួសារ)។

➢ **អំពើជួញដូរមនុស្ស:**

សរុបចំនួន០៥ករណី/០៧ករណី ជនសង្ស័យចំនួន០៧នាក់ ជនបរទេសចំនួន០១នាក់(សញ្ជាតិកូរ៉េ០១នាក់) ជនរងគ្រោះចំនួន២៨នាក់ អាយុក្រោម១៥ឆ្នាំចំនួន០៥នាក់ ,អាយុពី១៥-១៧ឆ្នាំចំនួន០៨នាក់ និងអាយុ១៨ឆ្នាំឡើងចំនួន១៥នាក់(ប្រគល់ឲ្យគ្រួសារ២០នាក់ និង០៨នាក់ប្រគល់ឲ្យមន្ទីរសង្គមកិច្ច) ។

-ការនាំយកអនីតិជនជាអាទិ៍ចេញដោយមិនស្របច្បាប់ ០២ករណី ជនសង្ស័យ ០២នាក់

-ការនាំយកចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន ០២ករណី ជនសង្ស័យ ០៤នាក់

-ការទិញពេស្យាចារកុមារ ០១ករណី ជនសង្ស័យ ០១នាក់ (សញ្ជាតិកូរ៉េ) ។

➢ **អំពើធ្វើអាជីវកម្មផ្លូវភេទ:**

សរុបចំនួន០៥ករណី/០៧ករណី ជនសង្ស័យចំនួន០៥នាក់ ជនរងគ្រោះចំនួន០៦នាក់ ក្នុងនោះអាយុក្រោម១៥ឆ្នាំចំនួន០៦នាក់ (ប្រគល់ឲ្យគ្រួសារ) ។

-អំពើអាសអាភាសប្រឆាំងនឹងអនីតិជនអាយុក្រោម១៥ឆ្នាំ ០១ករណី ជនសង្ស័យ ០១នាក់

-អំពើរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ ០៤ករណី ជនសង្ស័យ ០៤នាក់

**៤. ការងារកិច្ចការយុត្តិធម៌**

តាមទិន្នន័យដែលបានទទួលពីក្រុមការងារកិច្ចការយុត្តិធម៌ ដឹកនាំដោយក្រសួងយុត្តិធម៌ ដែលបានដកស្រង់លទ្ធផលពីសាលាដំបូងរាជធានី-ខេត្ត ការងារផ្តន្ទាទោសនៅក្នុងខែតុលា ឆ្នាំ២០១៦នេះ តុលាការរាជធានី-ខេត្ត បានធ្វើចំណាត់ការលើសំណុំរឿងបទល្មើសក្រោមច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទ និងមាត្រាពាក់ព័ន្ធនៃក្រមព្រហ្មទណ្ឌ ជាលទ្ធផលតាមដំណាក់កាលនៃនីតិវិធីតុលាការ មិនទាន់បានបូកសរុបលទ្ធផលនៅឡើយដោយរង់ចាំសរុបជារបាយការណ៍ត្រីមាសទី៤ ។

**៥. ការងារសហប្រតិបត្តិការអន្តរជាតិ**

+គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ្មាន)

+ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

-បានចូលរួមកិច្ចប្រជុំទ្វេភាគី រវាងប្រទេសកម្ពុជា និងប្រទេសវៀតណាម ដើម្បីពិនិត្យឡើងវិញលើកិច្ចព្រមព្រៀង (MOU) ស្តីពីផែនការសកម្មភាពរួម និងនីតិវិធីប្រតិបត្តិបទដ្ឋាន(SOP) កម្ពុជា-វៀតណាម ក្នុងការប្រយុទ្ធប្រឆាំងអំពើ

ជួញដូរមនុស្ស និងជួយជនរងគ្រោះដោយអំពើជួញដូរ ដែលមានការអញ្ជើញចូលរួមពីក្រុមការងារខេមមីតវៀតណាម ចំនួន២០រូប ក្រសួង/ស្ថាប័នពាក់ព័ន្ធ តំណាងខេត្តទាំង៧ជាប់ព្រំដែន និងដៃគូអភិវឌ្ឍន៍ មានចំនួនសរុប៨០នាក់ ។

-បានចូលរួមសិក្ខាសាលាថ្នាក់តំបន់ ស្តីពីការបង្កើតគោលការណ៍ណែនាំខមមីតសម្រាប់កំណត់អត្តសញ្ញាណជនរងគ្រោះ និងយន្តការបញ្ជូន នៅសណ្ឋាគារ LANMARK ទីក្រុងបាំងកក ប្រទេសថៃ ។

-បានចូលរួមកិច្ចប្រជុំពិភាក្សា អនុស្សារណៈនៃការយោគយល់ រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃ ស្តីពីការបង្កើតមជ្ឈមណ្ឌលសំចត និងទទួលជនរងគ្រោះ ដោយអំពើជួញដូរ និងក្រុមងាយរងគ្រោះដទៃទៀត នៅក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ។

+ក្រុមការងារអនុវត្តន៍ច្បាប់ ថ្នាក់ដឹកនាំនាយកដ្ឋានប្រឆាំងអំពើជួញដូរមនុស្ស និងការពារអនីតិជនចំនួន០៩រូប បានចូលរួមសិក្ខាសាលាថ្នាក់តំបន់លើកទី៤ ដើម្បីពិភាក្សា និងជំរុញការអនុវត្តកម្មវិធី AAPTIP ពាក់ព័ន្ធកិច្ចសហប្រតិបត្តិការ រវាងប្រទេសទាំង៤ កម្ពុជា ,ថៃ ,មីយ៉ាន់ម៉ា និងប្រទេសឥណ្ឌូនេស៊ី (នៅប្រទេសមីយ៉ាន់ម៉ា) ។

+**ខេត្តស្វាយរៀង គណៈកម្មាធិការ គ.ខ.ប.ជ ខេត្ត**

-បានដឹកនាំប្រតិភូក្រុមការងារលេខាធិការដ្ឋាន បានចូលរួមកិច្ចប្រជុំទ្វេភាគី រវាងប្រទេសកម្ពុជា និងប្រទេសវៀតណាម ស្តីពីកិច្ចសហប្រតិបត្តិការធ្វើសមាហរណកម្ម ដោយអំពើជួញដូរមនុស្ស បានចំនួន០១លើក នៅខេត្តព្រះសីហនុ ។

-បានពង្រឹងកិច្ចសហប្រតិបត្តិការទ្វេភាគីរវាងប្រទេសកម្ពុជា និងប្រទេសវៀតណាម ស្តីពីការអនុវត្តលើមូលដ្ឋានអនុសញ្ញាកិច្ចព្រមព្រៀង កិច្ចការពារព្រំដែន ដើម្បីបង្ក្រាប ទប់បទល្មើសការជួញដូរស្ត្រី និងកុមារ ធ្វើឲ្យសភាពការណ៍បទល្មើសមានការថយចុះ ។

+ខេត្តប៉ៃលិន ក្រុមការងារសហប្រតិបត្តិការអន្តរជាតិ បានសហការជាមួយអាជ្ញាធរថៃ ជួយសម្រួលដល់ក្រុមហ៊ុនដែលបានបញ្ជូនពលករខ្មែរទៅធ្វើការនៅប្រទេសថៃ បានចំនួន០៣លើក ក្នុងនោះ ៖

-នៅថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១៦ មានក្រុមហ៊ុន B.S.R.O BEST MANPOWER CO.LTD បានបញ្ជូនពលករទៅធ្វើការនៅប្រទេសថៃ ចំនួន៣១នាក់ ស្រីចំនួន១៦នាក់ ។

-នៅថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៦ មានក្រុមហ៊ុន B.S.R.O BEST MANPOWER CO.LTD បានបញ្ជូនពលករទៅធ្វើការនៅប្រទេសថៃ ចំនួន០៥នាក់ ស្រីចំនួន០២នាក់ ។

-នៅថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៦ មានក្រុមហ៊ុន CATM ASIA MANPOWER COOPERATION CO.LTD បានបញ្ជូនពលករទៅធ្វើការនៅប្រទេសថៃ ចំនួន៤៨នាក់ ស្រីចំនួន១៨នាក់ ។

### ៦. ការងារពាក់ព័ន្ធនឹងកុមារ

សកម្មភាពខិតខំប្រឹងប្រែង ក្នុងកិច្ចការការពារ និងជួយសង្គ្រោះដល់កុមារ ជាពិសេសកុមារងាយរងគ្រោះដោយអំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ និងការកេងប្រវ័ញ្ចលើកម្លាំងពលកម្មរបស់ គ.ជ.ប.ជ/គ.ខ.ប.ជ សរុបចំនួន១២នាក់ ក្នុងនោះកុមារា០៩នាក់ និងកុមារីចំនួន០៥នាក់) ។

+**មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្ត បន្ទាយមានជ័យ** បានចុះជួយកុមាររងគ្រោះដោយអំពើជួញដូរមនុស្ស ឲ្យស្នាក់នៅរយៈពេលខ្លី នៅមណ្ឌលស្តារនីតិសម្បទា ចំនួន១២នាក់(ក្នុងនោះមាន កុមារា០៩នាក់ និងកុមារីចំនួន០៣នាក់) ។

+**មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្តកណ្តាល** បានសហការជាមួយអង្គការមេត្រីអន្តរជាតិដើម្បីអាស៊ី បានធ្វើសមាហរណកម្មកុមារីចំនួន០២នាក់ រងគ្រោះដោយអំពើជួញដូរមនុស្ស នៅស្រុកស្អាង ក្រុងតាខ្មៅ បន្ទាប់ពីបានទទួលសេវាថែទាំព្យាបាល និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឲ្យទៅរស់នៅជួបជុំជាមួយឪពុកម្តាយវិញ ។

### ៧. ការងារទេសន្តរប្រវេសន៍

○តាមទិន្នន័យរបស់នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ បាន

ធ្វើការសម្ភាសពលករខ្មែរ និងជនបរទេស ដែលបានដាក់ពាក្យ សុំរៀបអាពាហ៍ពិពាហ៍បានចំនួន១១៣គូ និងបានសាកសួរសុខទុក្ខនារីខ្មែរ ដែលបានរៀបការរួចទៅនៅឯក្រៅប្រទេស ដោយបានទំនាក់ទំនងតាមរយៈទូរស័ព្ទផ្ទាល់របស់សាមីខ្លួនបានចំនួន១៦នាក់ (រស់នៅជាមួយគ្រួសារមានសេចក្តីសុខសប្បាយជាធម្មតា) ។

◦តាមទិន្នន័យរបស់នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ពលករទេសន្តប្រវេសន៍ទៅរកការងារធ្វើនៅក្រៅប្រទេសដែលបានគ្រប់គ្រងក្នុងខែតុលា ឆ្នាំ២០១៦ សរុបបានចំនួន៣១៣,២៨៥នាក់(ស្រីចំនួន១៤១,៦៩៥នាក់) អនីតិជន មានចំនួន៦,២០៨នាក់ (ស្រីចំនួន២,៣៦៩នាក់) ក្នុងនោះស្របច្បាប់ចំនួន១៧៣,០០៩នាក់(ស្រីចំនួន៨៤,៩៦១នាក់) និងអនីតិជនចំនួន៦៨៣នាក់ (ស្រីចំនួន២៧៥នាក់) មិនស្របច្បាប់ចំនួន១៤០,២៧៦នាក់(ស្រីចំនួន៥៦,៧៣៤នាក់ និងអនីតិជនចំនួន៥,៥២៥នាក់(ស្រីចំនួន២,០៩៤នាក់) បើប្រៀបធៀបនឹងខែមុនកើនចំនួន៤,២២៩នាក់ ស្មើនឹង១,៣៦% ។

**ខ.ការងារដឹកនាំសម្របសម្រួល**

ការងារដឹកនាំសម្របសម្រួលសរុបរួមបានចំនួន៤៨លើក ក្នុងខែតុលា ឆ្នាំ២០១៦ ដែលធ្វើឡើងដោយគណៈកម្មាធិការជាតិ គ.ជ.ប.ជ និងគណៈកម្មាធិការរាជធានី-ខេត្ត គ.រ.ប.ជ/គ.ខ.ប.ជ ។ (**ឧបសម្ព័ន្ធទី៧**)

**+សកម្មភាពលោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានចំនួន១០លើក៖**

- បានអញ្ជើញជួបសំណេះសំណាលជាមួយតំណាងស្ថានទូតសហរដ្ឋអាមេរិកប្រចាំកម្ពុជា ស្តីពីការប្រយុទ្ធ ប្រឆាំងអំពើជួញដូរមនុស្សនៅកម្ពុជា នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១៦ ។
- បានដឹកនាំកិច្ចប្រជុំពិភាក្សា ស្តីពី "ការសិក្សាអំពីផលប៉ះពាល់នៃទេសន្តប្រវេសន៍ចំពោះកុមារ ដែលធ្វើឡើងដោយអង្គការ UNICEF" នៅសាលប្រជុំ គ.ជ.ប.ជ ថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១៦ ។
- បានអញ្ជើញចូលរួមជាវាគ្មិនកិត្តិយស និងជាគណៈកម្មការវាយតម្លៃក្នុងទិវាភាពជាអ្នកដឹកនាំ ក្រោមប្រធានបទ "ភាពជាអ្នកបន្តវេន" នៅមជ្ឈមណ្ឌលសហប្រតិបត្តិការ កម្ពុជា-ជប៉ុន(CJCC) ថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៦ ។
- បានអញ្ជើញចូលរួមក្នុងពិធីចុះហត្ថលេខាលើឯកសារពាក់ព័ន្ធដល់កិច្ចសហប្រតិបត្តិកា រវាងក្រសួងមហាផ្ទៃ នៃព្រះរាជាណាចក្រកម្ពុជា និងក្រសួងសន្តិសុខសាធារណៈ នៃសាធារណៈរដ្ឋប្រជាមានិតចិន ស្តីពី "កិច្ចព្រមព្រៀងលើការពង្រឹងកិច្ចសហប្រតិបត្តិការក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស" នៅវិមានសន្តិភាព ថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៦ ។
- បានដឹកនាំកិច្ចប្រជុំត្រៀមរៀបចំទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស១២ធ្នូ ២០១៦ នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៦ ។
- បានដឹកនាំកិច្ចប្រជុំពិភាក្សាអន្តរក្រសួង ស្តីពីការផ្តល់សំណងដល់ជនរងគ្រោះ នីតិវិធីជំនួយផ្នែកច្បាប់ និងការផ្តល់ទីកន្លែងសម្រាប់ប្រព្រឹត្តអំពើជួញដូរមនុស្ស ដើម្បីដាក់ចូលទៅក្នុងសិក្ខាសាលាថ្នាក់ជាតិ នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១៦ ។
- បានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំក្រុមការងារចំពោះកិច្ច ពិភាក្សាលើអនុក្រឹត្យ ស្តីពីជនភៀសខ្លួន និងកែសម្រួលលើអនុស្សរណៈរវាងរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាល សហរដ្ឋអាមេរិក ស្តីពី "ការបង្កើត និងកិច្ចប្រតិបត្តិការរបស់គណៈកម្មការរួមធ្វើមាតុភូមិនិវត្តន៍ ដែលបានចុះហត្ថលេខាកាលពីថ្ងៃទី២២ ខែមីនា ឆ្នាំ២០០២" នៅទីស្តីការក្រសួងមហាផ្ទៃ ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៦ ។
- បានអញ្ជើញជាអធិបតី និងវាគ្មិនក្នុងវគ្គបណ្តុះបណ្តាល ស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីទទួលបានសេវាសមស្រប ដែលវគ្គនេះឧបត្ថម្ភ និងរៀបចំដោយអង្គការដែនដីមនុស្សហូឡង់ និងសម្របសម្រួលដោយ គ.ជ.ប.ជ នៅសណ្ឋាគារអាស៊ីធូន(Asia Tune) មានសិក្ខាកាមចូលរួមសរុប ២៥នាក់ (ស្រី៨នាក់) ថ្ងៃទី២៥-២៧ ខែតុលា ឆ្នាំ២០១៦ ។
- បានដឹកនាំកិច្ចប្រជុំត្រៀមរៀបចំទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ ២០១៦ នៅសាលប្រជុំអគ្គលេខាធិការដ្ឋានគ.ជ.ប.ជ ថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៦ ។

- បានអញ្ជើញជាអធិបតីនៅក្នុងពិធីបើក និងជាគ្រូឧទ្ទេសនៃវគ្គបណ្តុះបណ្តាលគ្រូបង្គោល ស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប នៅសាលាខេត្តបន្ទាយមានជ័យ ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៦ ។

## ឃ. ការលើកកម្ពស់សមត្ថភាព

### ១.ការបណ្តុះបណ្តាល

+ក្រុមការងារអនុវត្តន៍ច្បាប់

-នាយកដ្ឋានប្រឆាំងអំពើជួញដូរមនុស្ស និងការពារអនីតិជន បានសហការជាមួយអង្គការ (CPU) បានបើកវគ្គបណ្តុះបណ្តាល ស្តីពីការសម្ភាសកុមារ បានចំនួន០១លើក មានសិក្ខាកាមចូលរួមចំនួន២៤នាក់ ស្រីចំនួន២១នាក់ នៅអគារ (ICON ) ។

-ស្នងការដ្ឋាននគរបាលខេត្តស្វាយរៀង បានបើកវគ្គបណ្តុះបណ្តាល ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងទេសន្តរប្រវេសន៍ ចំនួន០១លើក មានសិក្ខាកាមចូលរួមចំនួន៣៩នាក់ ។

### ២. សិក្ខាសាលា

+គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

- ក្រុមជំនួយកិច្ចការពារជនរងគ្រោះបានបើកវគ្គបណ្តុះបណ្តាល ស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីទទួលបានសេវាសមស្រប ក្រោមអធិបតីភាព លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជា អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ។ មានការរៀបចំ និងឧបត្ថម្ភដោយអង្គការវេដនដីមនុស្សហូឡង់ និងសម្របសម្រួលដោយ គ.ជ.ប.ជ នៅសណ្ឋាគារអាស៊ីធូន(Asia Tune) មានសិក្ខាកាមចូលរួមសរុប ២២នាក់ (ស្រី៨នាក់) ថ្ងៃទី២៥-២៧ ខែតុលា ឆ្នាំ២០១៦ ។

+ក្រុមការងារអនុវត្តន៍ច្បាប់ ស្នងការដ្ឋាននគរបាលខេត្តស្វាយរៀង បានរៀបចំសិក្ខាសាលាថ្នាក់ខេត្ត ស្តីពីការពាក់ព័ន្ធនឹងពលកម្មកុមារ ចំនួន០១លើក មានសិក្ខាកាមចូលរួមចំនួន២២នាក់ ស្រីចំនួន១៦នាក់ ។

## III. ការវាយតម្លៃ

### ក.ចំណុចខ្លាំង

តាមរយៈការខិតខំប្រឹងប្រែង ក្នុងខែតុលា ឆ្នាំ២០១៦នេះ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ សម្រេចបានការងារជាលទ្ធផលជោគជ័យគួរឲ្យកត់សម្គាល់៖

១. បានប្រកាសជាផ្លូវការ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ គណៈកម្មាធិការរាជធានី-ខេត្ត គ.រ.ប.ជ/គ.ខ.ប.ជ លេខាធិការដ្ឋាន គ.រ.ប.ជ/គ.ខ.ប.ជ ប្រកាសសេចក្តីសម្រេចកំណត់តួនាទី ភារកិច្ចរួមជាស្រេច។

២. បានដាក់ចុះផែនការសកម្មភាពជាតិរបស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) សម្រាប់រយៈ ពេល៥ ឆ្នាំ (២០១៤-២០១៨) ជាផែនទីបង្ហាញផ្លូវ ។

៣. បានរៀបចំក្រុមការងារអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ នឹងបន្តសកម្មភាពដឹកនាំជាយុទ្ធសាស្ត្រ របស់ក្រុមការងារទាំង៦ និងថ្នាក់ក្រោមជាតិ ព្រមទាំងពង្រឹងកិច្ចសហប្រតិបត្តិការរួមគ្នា លើកវិធានការ ការងារបង្ការទប់ស្កាត់និង បង្ក្រាបបទល្មើសជួញដូរមនុស្ស ។

៤.បានបង្កើនកិច្ចសហប្រតិបត្តិការ ជាមួយអន្តរក្រសួង ស្ថាប័ននានា ក្នុងដំណើរការសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

៥. កិច្ចខិតខំប្រឹងប្រែងរបស់ក្រុមការងារអនុវត្តន៍ច្បាប់ ដែលបានអនុវត្តទៅតាមតួនាទី និងភារកិច្ចដែលបានដាក់ចុះសម្រេចបាននូវលទ្ធផលគួរឲ្យកត់សម្គាល់។

៦. បានខិតខំស្វែងរកការគាំទ្រ និងកិច្ចសហការពីអង្គការជាតិ អន្តរជាតិ ជាដៃគូនានា សំដៅអនុវត្តសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឲ្យកាន់តែមានប្រសិទ្ធភាព។

**ខ.ចំណុចសេសសល់ និងភាពប្រឈម**

ទន្ទឹមនឹងការខិតខំប្រឹងប្រែង និងចំណុចខ្លាំងខាងលើ យើងពិនិត្យឃើញនៅមានចំណុចប្រឈម នឹងសេសសល់មួយចំនួនដូចជា ៖

- ក្រុមការងារអន្តរក្រសួងស្ថាប័ន ព្រមទាំងលេខាធិការដ្ឋានរាជធានី-ខេត្ត មួយចំនួនមិនទាន់បានផ្ញើរបាយការណ៍ប្រចាំខែ តាមការកំណត់ របស់ គ.ជ.ប.ជ នៅឡើយ ។
- ត្រូវពង្រឹងសមត្ថភាពដល់មន្ត្រីបំពេញការងារបន្ថែមទៀត ដោយមូលហេតុមានការផ្លាស់ប្តូរ សមាសភាព និងការរៀបចំជាថ្មីនូវរចនាសម្ព័ន្ធតាមបណ្តាថ្នាក់ ។
- សមត្ថភាព និងធនធានមួយចំនួនដែលចាំបាច់សម្រាប់ការអនុវត្តច្បាប់នៅមានកម្រិត ដែលទាមទារឲ្យពង្រឹងបន្ថែម ទើបអាចឆ្លើយតបទៅនឹងសភាពការណ៍នៃបទល្មើស ។
- កិច្ចសហការពីអ្នកពាក់ព័ន្ធ ក្នុងនោះមានជនរងគ្រោះ នៅមិនទាន់ឆ្លើយតបទាន់សភាពការណ៍ ។
- ការទទួលព័ត៌មាន និងការអប់រំ ផ្សព្វផ្សាយ អំពីកលល្បិចរបស់ជនខិលខូចនៅមិនទាន់បានទូលំទូលាយនៅឡើយសម្រាប់ប្រជាពលរដ្ឋ ជាពិសេសប្រជាពលរដ្ឋ ដែលរស់នៅតំបន់ជនបទដាច់ស្រយាលដែលជាចំណុចចន្លោះប្រហោងមួយសម្រាប់ពួកឈ្មួញទុច្ចរិតងាយធ្វើការអូសទាញ បោកបញ្ឆោតទាំង បុរស ស្ត្រី និងកុមារ ឲ្យជឿជាក់និងធ្វើទេសន្តរប្រវេសន៍ដោយខុសច្បាប់ ។
- ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋមានការខ្វះខាត ហើយចំណេះដឹងនិងការអប់រំ របស់ពួកគាត់នៅមានកម្រិតដូច្នេះទើបធ្វើឲ្យពួកគាត់ ធ្វើការសម្រេចចិត្តរួសរាន់ទៅតាមការអូសទាញរបស់ឈ្មួញទុច្ចរិត។
- រចនាសម្ព័ន្ធ នៃគណៈកម្មាធិការរាជធានី/ខេត្ត និងលេខាធិការដ្ឋានថ្នាក់ក្រោមជាតិមួយចំនួន មិនទាន់បានរៀបចំត្រឹមត្រូវច្បាស់លាស់ ក្នុងការធ្វើការតាមដានការងារជាប្រចាំ និងពុំទាន់មានថវិកាគ្រប់គ្រាន់សម្រាប់ចំណាយលើការងារថ្នាក់ក្រោមជាតិ ។
- អង្គការជាតិ និងអន្តរជាតិមួយចំនួន នៅមិនទាន់ចូលរួមពេញលេញក្នុងការអនុវត្តយន្តការ និងសកម្មភាពរួមនេះ ហើយបានធ្វើសកម្មភាពដោយឡែក ដែលមិនឆ្លើយតបនឹងគោលដៅ នៃការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ។

## IV.ទិសដៅសម្រាប់ខែវិច្ឆិកា ឆ្នាំ ២០១៦

១. ជំរុញការអនុវត្តអនុសាសន៍ដ៏ខ្ពង់ខ្ពស់ ០៤ចំណុចរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ថ្លែងក្នុងទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ ធ្នូ ឆ្នាំ២០១៥ នៅសាលមហោស្រព នៃមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ និងគោលការណ៍ណែនាំរបស់រាជ រដ្ឋាភិបាល លេខ០០១ គកន ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៣ ស្តីពីការគ្រប់គ្រងកម្លាំងពលកម្ម និងលំហូរទេសន្តរប្រវេសន៍ ។

២. បន្តជំរុញអនុវត្ត វិធានការ ០៦ចំណុច របស់**សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

៣. រៀបចំសកម្មភាពវាយតម្លៃផែនការសកម្មភាពជាតិ ២០១៤-២០១៨ ពាក់កណ្តាលអាណត្តិ និងកែលម្អសកម្មភាពជំហានបន្តរហូតដល់ឆ្នាំ២០១៨ ។

៤. បន្តសកម្មភាពបណ្តុះបណ្តាលមន្ត្រី ពាក់ព័ន្ធ នឹងការកំណត់អត្តសញ្ញាណជនរងគ្រោះ តាមបណ្តាក្រសួង មន្ទីរ ស្ថាប័ន អង្គការដៃគូក្នុងស្រុក និងមន្ត្រីប្រចាំស្ថានទូតកម្ពុជា ក្នុងប្រទេសគោលដៅ និងជំរុញការអនុវត្តបន្ត ។

៥. ត្រៀមសេចក្តីព្រាងផែនការអនុវត្តកិច្ចព្រមព្រៀងទ្វេភាគី កម្ពុជា-ចិន ស្តីពីការពង្រឹងកិច្ចសហប្រតិបត្តិការបង្ការទប់ស្កាត់ និងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ។

៦. ធ្វើការស្រាវជ្រាវ អំពីកាលានុវត្តភាពការងារជាជម្រើសរបស់ពលករកម្ពុជាក្នុងនិងក្រៅប្រទេស និងស្វែងយល់ពីកត្តារុញច្រាន និងអូសទាញ ដើម្បីរៀបចំផែនការបង្ការទប់ស្កាត់ ។

៧. ត្រៀមពិនិត្យ កិច្ចព្រមព្រៀង ទ្វេភាគី កម្ពុជា-ឥណ្ឌា តាមការស្នើសុំរបស់ រដ្ឋាភិបាលឥណ្ឌា ។

៨. ត្រៀមកិច្ចប្រជុំពិគ្រោះយោបល់ រវាងក្រុមប្រទេសបញ្ជូន និងប្រទេសទទួល(ថៃ ម៉ាឡេស៊ី..) ដើម្បីពង្រឹងកិច្ចសហការ ដើម្បីចែករំលែកការទទួលខុសត្រូវ និងការពារផលប្រយោជន៍ពលករ និយោជក និងរវាងប្រទេសបញ្ជូន និង ប្រទេសទទួល ប្រកបដោយសមធម៌ ។

៩. បន្តពង្រឹងកិច្ចសហការទូលំទូលាយ ឆ្ពោះទៅកាន់គោលដៅរួម គឺការបង្ការទប់ស្កាត់ ឈានទៅលុបបំបាត់អំពើជួញ ដូរមនុស្ស ក្នុងព្រះរាជាណាចក្រកម្ពុជា និងទៅលើប្រជាជនកម្ពុជា ។

១០. ជំរុញការអនុវត្តច្បាប់ គោលនយោបាយ និងបទដ្ឋានគតិយុត្តនានា ទៅតាមមុខសញ្ញានៃក្រសួង ស្ថាប័ន និង អង្គភាពដែលទទួលខុសត្រូវ ឈានទៅធ្វើឲ្យសម្រេចគោលដៅរបស់រាជរដ្ឋាភិបាលក្នុងការប្រយុទ្ធប្រឆាំងអំពើជួញ ដូរមនុស្ស ។

១១. សម្របសម្រួល ពង្រឹង និងពង្រីកកិច្ចសហការឲ្យបានទូលំទូលាយជាមួយគ្រប់ផ្នែក គ្រប់វិស័យ និងរវាងរាជរដ្ឋា ភិបាល និងដៃគូពាក់ព័ន្ធ អង្គការជាតិ និងអន្តរជាតិ សង្គមស៊ីវិល ផ្នែកឯកជន ដើម្បីអនុវត្ត យុទ្ធសាស្ត្រ ដែលបាន គ្រោងទុកក្នុងផែនការជាតិ ផែនការរបស់ក្រុមការងារទាំងប្រាំមួយ និងផែនការរាជធានី/ខេត្ត ។

១២. គាំទ្រ និងពង្រឹងសមត្ថភាព របៀបរបបការងាររបស់ក្រុមការងារ និងលេខាធិការដ្ឋានរាជធានី/ខេត្ត ។

១៣. បន្តការងារផ្សព្វផ្សាយ អប់រំ តាមគ្រប់រូបភាព និងប្រើគ្រប់លទ្ធភាព និងធនធាន ដើម្បីលើកកម្ពស់ការ យល់ដឹងជា សកល អំពីអំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មផ្លូវភេទ ការជួញដូរ និងការកេងប្រវ័ញ្ចកម្លាំងពលកម្ម ទំនាក់ទំនង រវាងទេសន្តរប្រវេសន៍ និងអំពើជួញដូរមនុស្ស និងបទល្មើសពាក់ព័ន្ធដទៃទៀត ឲ្យបានដល់ប្រជាពលរដ្ឋ ជា ពិសេសស្រទាប់យុវវ័យ និងជនដែលងាយរងគ្រោះ ។

រាជធានីភ្នំពេញ ថ្ងៃទី.........ខែ..................ឆ្នាំ២០១៦

**អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

ជូ ប៊ុនអេង

ចម្លងជូន

-ខុទ្ទកាល័យសម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង មហាផ្ទៃនិងជាប្រធាន គ.ជ.ប.ជ

"ដើម្បីគោរពជូនជាសេចក្តីរាយការណ៍"

-ឯកឧត្តម លោកជំទាវ ប្រធានក្រុមការងារជំនាញ អន្តរក្រសួង ស្ថាប័ន

-សមាជិកក្រុមការងារ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ "ដើម្បីជូនជ្រាប"

-ឯកសារ កាលប្បវត្តិ

# ឧបសម្ព័ន្ធទី១

## ការខារផ្សព្វផ្សាយ

| ល.រ | អង្គភាព | សកម្មភាព | អ្នកពាក់ព័ន្ធ | លើក | ចំនួនមនុស្ស | ស្រី |
|---|---|---|---|---|---|---|
| 1 | ក្រុមការងារអនុវត្តន៍ច្បាប់ | ស្នងការដ្ឋាននគរបាលខេត្តស្វាយរៀង ,កំពង់ចាម ,សៀមរាប និងឧត្តរមានជ័យ បានធ្វើការផ្សព្វផ្សាយស្តីពីច្បាប់ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ ដល់ភូមិ/ឃុំមានសុវត្ថិភាព ដល់ម្ចាស់អាជីវកម្ម អាជ្ញាធរមូលដ្ឋាន ប្រជាពលរដ្ឋ លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស ។ | ស្នងការដ្ឋាននគរបាលខេត្ត | 395 លើក | 44,446 នាក់ | 26,594 នាក់ |
| 2 | កណ្តាល | ក្រុមការងារថ្នាក់ស្រុក បានធ្វើការផ្សព្វផ្សាយច្បាប់ ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសា ការទប់ស្កាត់អំពើជួញដូរស្ត្រី និងកុមារ និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព ដល់ក្រុមការងារថ្នាក់ ភូមិ-ឃុំ ដល់ប្រជាពលរដ្ឋបានយល់ដឹងគ្រប់ៗគ្នា ។ | ក្រុមការងារថ្នាក់ស្រុក | 9 លើក | 1,445 នាក់ | 897 នាក់ |
| | | ក្រុមការងារថ្នាក់ស្រុក បានធ្វើការផ្សព្វផ្សាយច្បាប់ ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសា ការទប់ស្កាត់អំពើជួញដូរស្ត្រី និងកុមារ និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព ដល់ក្រុមការងារថ្នាក់ ភូមិ-ឃុំ ដល់ប្រជាពលរដ្ឋបានយល់ដឹងគ្រប់ៗគ្នា ។ | លេខាធិការដ្ឋាន គ.ខ.ប.ជ និងក្រុមការងារថ្នាក់ស្រុក | 17 លើក | 474 នាក់ | 210 នាក់ |
| 3 | កំពង់ស្ពឺ | ការិយាល័យជំនាញបានសហការជាមួយកម្លាំងអធិការដ្ឋាននគរបាលអាជ្ញាធរមូលដ្ឋាន ស្រុក គងពិសី ចុះផ្សព្វផ្សាយច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្សការធ្វើអាជីវកម្មផ្លូវភេទ ច្បាប់ទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ ជូនដល់ប្រជាពលរដ្ឋអោយបានយល់ដឹងគ្រប់ៗគ្នា ។ | ស្នងការដ្ឋាននគរបាលខេត្ត និងក្រុមការងារថ្នាក់ស្រុក | 6 លើក | 424 នាក់ | 150 នាក់ |
| 4 | តាកែវ | ចុះផ្សព្វផ្សាយច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្សការធ្វើអាជីវកម្មផ្លូវភេទ ការរំលោភសេព សន្ធៈច្បាប់ទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ ជូនដល់ប្រជាពលរដ្ឋអោយបានយល់ដឹងគ្រប់ៗគ្នា ។ | មន្ទីកិច្ចការនារីខេត្ត | 4 លើក | 224 នាក់ | 182 នាក់ |
| | | ក្រុមការងារថ្នាក់ស្រុក បានធ្វើការផ្សព្វផ្សាយច្បាប់ ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសា ការទប់ស្កាត់អំពើជួញដូរស្ត្រី និងកុមារ និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព ដល់ក្រុមការងារថ្នាក់ ភូមិ-ឃុំ ដល់ប្រជាពលរដ្ឋបានយល់ដឹងគ្រប់ៗគ្នា ។ | ស្នងការដ្ឋាននគរបាលខេត្ត | 128 លើក | 6,396 នាក់ | 2,210 នាក់ |
| | | បានចុះផ្សព្វផ្សាយវេទិកាសាធារណៈ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារក្នុងការអនុវត្តន៍គោលនយោបាយភូមិឃុំមានសុវត្ថិភាព នៅតាមបណ្តាល ក្រុង ស្រុក ដល់ប្រជាពលរដ្ឋអោយបានយល់ដឹងគ្រប់គ្នា ។ | | 122 លើក | 5,534 នាក់ | 1,938 នាក់ |

| | | | | | | |
|---|---|---|---|---|---|---|
| 5 | កំពង់ធំ | ក្រុមការងារទី៣ របស់លេខាធិការដ្ឋានបានផ្សព្វផ្សាយច្បាប់ទប់ស្កាត់អំពើហិង្សា និងអំពើជួញដូរមនុស្ស វិធីសាស្ត្រធ្វើចំណាក់ស្រុកដោយសុវត្ថិភាព និងគោលនយោបាយភូមិឃុំមានសុវត្ថិភាព ដល់អាជ្ញាធរ មូលដ្ឋាន ប្រជាពលរដ្ឋ លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស នៅស្រុកសន្ទុក ស្រុកស្ទោង ។ | លេខាធិការដ្ឋានស្រុក | 2 លើក | 303 នាក់ | 134 នាក់ |
| 6 | ព្រះវិហារ | បានធ្វើការផ្សព្វផ្សាយច្បាប់ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ បញ្ជ្រាបគោលនយោបាយភូមិ/ឃុំមានសុវត្ថិភាព ដល់មន្ត្រី រាជការ ប្រជាជន សិស្សានុសិស្ស បានយល់ដឹងគ្រប់ៗគ្នា មានចំនួន ១៨លើក លើ០៩ឃុំ ០៤ស្រុក ។ | គណៈកម្មាធិការ គ.ខ.ប.ជ<br>ស្នងការដ្ឋាននគរបាលខេត្ត | 18 លើក | 1,494 នាក់ | 473 នាក់ |
| 7 | បាត់ដំបង | បានចុះផ្សព្វផ្សាយ និងវេទិការសាធារណៈស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ ការអនុវត្តន៍គោលណយោបាយភូមិឃុំមានសុវត្ថិភាពដល់កងកម្លាំងប្រដាប់អាវុធ មន្ត្រីរាជការ និងប្រជាពលរដ្ឋ ។ | ស្នងការដ្ឋាននគរបាលខេត្ត | 269 លើក | 24,041 នាក់ | 11,625 នាក់ |
| 8 | បន្ទាយមានជ័យ | កំលាំងការិយាល័យជំនាញសហការជាមួយ កំលាំងអធិការដ្ឋានស្រុកថ្មពួក ស្រុកម៉ាឡៃ (ប៉ុស្តិ៍បឹងបេង ) អធិការដ្ឋាននគរបាលស្រុកអូរជ្រៅ (ប៉ុស្តិ៍អូរបីជាន់ )និងកំលាំងវរៈសេនាតូចការពារព្រំដែនគោក ៩១១ បានធ្វើការហាមឃាត់ពលរដ្ឋធ្វើការចំណាក់ស្រុកឆ្លងដែនខុសច្បាប់ទៅរកការងារធ្វើនៅប្រទេសថៃ តាមបន្ទាត់ព្រំដែនកម្ពុជា ថៃ មកពីខេត្ត ចំនួន ៤ ខេត្ត សៀមរាបចំនួន ៩២នាក់ ៩ស្រី ៤៥នាក់) កំពង់ធំ ៦២នាក់ ស្រី ២២នាក់ បាត់ដំបង ០២នាក់ ស្រី ០១នាក់ បន្ទាយមានជ័យ (៨៨នាក់ ស្រី៤៤នាក់ ) ។ | ស្នងការដ្ឋាននគរបាលខេត្ត | 4 លើក | 244 នាក់ | 112 នាក់ |
| 9 | រតនៈគីរី | ក្រុមការងារអនុវត្តន៍ច្បាប់ របស់ស្នងការដ្ឋាននគរបាលខេត្ត បានអនុវត្តគោលនយោបាយភូមិ ឃុំ មានសុវត្ថិភាព និង វេទិការសារធារណៈធ្វើការបញ្ជ្រាបច្បាប់ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ ការធ្វើចំណាក់ស្រុកប្រកបដោយសុវត្ថិភាព ប្រជាពលរដ្ឋចូលរួមបានយល់ដឹង ។ | ស្នងការដ្ឋាននគរបាលខេត្ត | 4 លើក | 655 នាក់ | 245 នាក់ |

| | | | | | | |
|---|---|---|---|---|---|---|
| 10 | ព្រះសីហនុ | ក្រុមការងារ គ.ខ.ប.ជ បានសហការជាមួយអាជ្ញាធរក្រុង/ស្រុកផ្សព្វផ្សាយគោលនយោបាយ ភូមិ ឃុំ មានសុវត្ថិភាព និងអង្គការដៃគូរ ផ្សព្វផ្សាយអំពីការរំលោភបំពានផ្លូវភេទ បានធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ ការចំណាក់ស្រុកខុសច្បាប់ ជូនដល់ប្រជាពលរដ្ឋ កងកំលាំងប្រដាប់អាវុធ អាជ្ញធរភូមិ ក្រុមប្រឹក្សាឃុំ សង្កាត់ មន្ត្រីរាជការ អង្គការ សង្គមស៊ីវិល លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស ។ | គណៈកម្មាធិការ គ.ខ.ប.ជ | 2 លើក | 74 នាក់ | 49 នាក់ |
| | | ក្រុមការងារបានចូលរួមផ្សព្វផ្សាយច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ ដល់អាជីវករ និងប្រជាពលរដ្ឋ នៅក្រុងព្រះសីហនុ ។ | | 1 លើក | 91 នាក់ | 32 នាក់ |
| | | ក្រុមការងារបានចូលរួមផ្សព្វផ្សាយវេទិកាសាធារណៈ នៅក្នុងភូមិឃុំមានសុវត្ថិភាព ដល់កំលាំងសមត្ថកិច្ច មន្ត្រីរាជការ អង្គការ សង្គមស៊ីវិល លោកគ្រូ /អ្នកគ្រូ និងប្រជាពលរដ្ឋ ។ | | 3 លើក | 237 នាក់ | 57 នាក់ |

សកម្មភាពសរុបៈចំនួន 984 លើក

មនុស្សសរុបចំនួនៈ 86,082 នាក់

ស្រីសរុបចំនួន : 44,908 នាក់

# តារាងឧបសម្ព័ន្ធទី៧
# ការងារដឹកនាំសម្របសម្រួល

| ល.រ. | អង្គភាព | សកម្មភាព | លើក | អ្នកពាក់ព័ន្ធ |
|---|---|---|---|---|
| ១ | គណៈកម្មាធិការជាតិ គ.ជ.ប.ជ | - ថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៦ បានដឹកនាំកិច្ចប្រជុំ ស្តីពីសំណាងដល់ជនរងគ្រោះ នីតិវិធីជំនួយផ្នែកច្បាប់ និងការផ្តល់ទីតាំងសម្រាប់ប្រព្រឹត្តបទល្មើសជួញដូរមនុស្ស នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ។<br>- ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៦ បានដឹកនាំកិច្ចប្រជុំស្តាប់សេចក្តីរាយការណ៍ស្តីពីលទ្ធផលការងាររបស់ក្រុមជំនួយកិច្ចការទាំង៦ នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ។<br>- ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៦ បានដឹកនាំកិច្ចប្រជុំស្តាប់សេចក្តីរាយការណ៍ស្តីពីលទ្ធផលការងាររបស់ក្រុមជំនួយកិច្ចការទាំង៦ នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ។<br>- ថ្ងៃទី២៥-២៧ ខែតុលា ឆ្នាំ២០១៦ បានអញ្ជើញចូលរួមសិក្ខាសាលាការបង្កើតផែនការសកម្មភាព និងផែនការថវិកាសម្រាប់គណៈកម្មការការពារកុមារថ្នាក់ជាតិ នៅខេត្តព្រះសីហនុ ។<br>- បានដឹកនាំត្រួតពិនិត្យវត្តមាន វិន័យ និងសណ្តាប់ធ្នាប់របស់មន្ត្រីនគរបាល និងមន្ត្រីស៊ីវិលនៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ នៅរៀងរាល់ព្រឹកថ្ងៃច័ន្ទ ។<br>- ថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៦ បានចូលរួមប្រជុំស្តីពីការបង្កើតវេបសាយរបស់ គ.ជ.ប.ជ ក្រោមអធិបតីភាព លោកជំទាវ រ៉ែន សិរីលក្ខិណា អគ្គលេខាធិការរង គ.ជ.ប.ជ ។ | ០៦ លើក | អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ |
| | | - លិខិតរបស់ គ.ជ.ប.ជ ៖ លិខិតចេញ(២២ច្បាប់) លិខិតចូល(០៧ច្បាប់) , លិខិតរបស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖ លិខិតចេញ(២២ច្បាប់) លិខិតចូល(២៨ច្បាប់) ស្រង់វត្តមានប្រចាំថ្ងៃ ដើម្បីតាមដានការងារប្រចាំថ្ងៃរបស់មន្ត្រី ។<br>- ធ្វើរបាយការណ៍ប្រចាំសប្តាហ៍ និងខែ របស់អគ្គលេខាធិការដ្ឋាន គ ជ.ប.ជ., ធ្វើកំណត់ហេតុ នៅរៀងរាល់កិច្ចប្រជុំ ។<br>- រៀបចំ និងបញ្ជូនលិខិតអញ្ជើញចូលរួមប្រជុំ ទៅកាន់ក្រសួង ស្ថាប័ន អង្គភាព រាជធានី-ខេត្ត និងអង្គការដៃគូពាក់ព័ន្ធនានា , ប្រមូលរបាយការណ៍តាមបណ្តាអន្តរក្រសួង ស្ថាប័ន និងរាជធានី/ខេត្តទាំង២៥ ។ | ៥លើក | លេខាធិការដ្ឋាន គ.ជ.ប.ជ |

| | | | | |
|---|---|---|---|---|
| | | - បញ្ចប់បូកសរុបរបាយការណ៍ខែកញ្ញា ឆ្នាំ២០១៦ របស់ គ.ជ.ប.ជ, បូកសរុបរបាយការណ៍១០ខែ ឆ្នាំ២០១៦ របស់ គ.ជ.ប.ជ ។<br>- រៀបចំធ្វើព្រឹត្តបត្តិព័ត៌មាន និងខិតប័ណ្ណផ្សព្វផ្សាយ ,រក្សាទុករូបភាព និងសកម្មភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិចូលក្នុងបណ្ណាសារ Wiki ,គ្រប់គ្រងទំព័រ facebook របស់លោកជំទាវអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ។<br>- ស្រាវជ្រាវព័ត៌មានពីមជ្ឈដ្ឋានផ្សេងៗ ជាពិសេសព័ត៌មាន និង comment ផ្សេងៗ ពាក់ព័ន្ធនឹងអំពើជួញដូរ មនុស្សលើទំព័រ facebook ,ប្រមូលរបាយការណ៍តាមបណ្តារាជធានី/ខេត្ត តាមប្រព័ន្ធ Telegram និង Gmail ។ | | |
| | គណៈកម្មាធិការជាតិ គ.ជ.ប.ជ | - បានពិនិត្យ និងតាមដានព័ត៌មានជាប្រចាំពីសកម្មភាពការបើកវេទិកាផ្សព្វផ្សាយ និងវគ្គបណ្តុះបណ្តាល លើការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស តាមបណ្តារាជធានី-ខេត្ត តាមរយៈTelegram ។ | ១លើក | ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ |
| | | - ថ្ងៃទី៣១ ខែតុលា ដល់០២ ខែវិច្ឆិកា ឆ្នាំ២០១៦ រៀបចំវគ្គបណ្តុះបណ្តាល ស្តីពីការកំណត់អត្តសញ្ញាណ ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីទទួលបានសេវាសមស្រប នៅខេត្តបន្ទាយមានជ័យ ។<br>- បានស្រង់ឈ្មោះជនរងគ្រោះដែលបញ្ជូនមកពីក្រៅប្រទេស តាមរយៈក្រសួងការបរទេស មានចំនួន ១៩នាក់ (ស្រី ០៨នាក់) ក្នុងនោះ៖<br>• មកពីប្រទេសម៉ាឡេស៊ី ចំនួន ០២នាក់ (ស្រី ០១នាក់)<br>• មកពីប្រទេសថៃ ចំនួន ០៤នាក់ (ស្រី) មកពីប្រទេសចិន ចំនួន ១៣នាក់ (ស្រី ០៣នាក់) | ២លើក | ក្រុមជំនួយកិច្ចការការពារជនរងគ្រោះ |
| | | - តាមដានសកម្មភាពការងារ និងប្រមូលរបាយការណ៍ពាក់ព័ន្ធនឹងការងារអនុវត្តច្បាប់នៅតាមបណ្តារាជធានី-ខេត្ត និងទំនាក់ទំនងសហការជាមួយក្រុមការងារអនុវត្តច្បាប់ ដែលដឹកនាំដោយអគ្គស្នងការដ្ឋាននគរបាលជាតិ ។ | ១លើក | ក្រុមការងារអនុវត្តច្បាប់ |
| | | - សិក្សាស្វែងយល់អំពីច្បាប់ ស្តីពីយុត្តិធម៌អនីតិជន ។<br>- ទំនាក់ទំនងក្រសួងយុត្តិធម៌ ដើម្បីស្នើសុំរបាយការណ៍១០ខែ ឆ្នាំ២០១៦ របស់ក្រុមការងារយុត្តិធម៌ ។ | ២លើក | ក្រុមជំនួយកិច្ចការយុត្តិធម៌ |
| | | - តាមដានសកម្មភាពការងារ និងប្រមូលរបាយការណ៍ របស់ក្រុមការងារទំនាក់ទំនងអន្តរជាតិ ដែល ដឹកនាំដោយក្រសួងកិច្ចការនារី ។ | ១លើក | ក្រុមទំនួយកិច្ចការអន្តរជាតិ |

| | | | | |
|---|---|---|---|---|
| | គណៈកម្មាធិការជាតិ គ.ជ.ប.ជ | - ថ្ងៃទី០៧ ខែតុលា ឆ្នាំ២០១៦ បានចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីការអង្កេតស្វែងយល់ទីផ្សារ រៀបចំ ដោយ Camboica-ACTs ដើម្បីបង្កើនសមត្ថភាពក្រុមការងារចុះអង្កេត និងសម្ភាសន៍ប្រជាពលរដ្ឋ ដែលមានអាយុ១៥ឆ្នាំដល់២៥ឆ្នាំ នៅក្នុងខេត្តចំនួន៣ (ត្បូងឃ្មុំ សៀមរាប និងរតនៈគីរី) សំដៅកាត់ បន្ថយភាពងាយរងគ្រោះដោយអំពើជួញដូរមនុស្ស និងចង់ឲ្យដឹងច្បាស់ថាព័ត៌មានការងារដែលទទួល បានពីថ្នាក់ជាតិ គឺបង្កលក្ខណៈងាយស្រួលដល់ពលករទេសន្តរប្រវេសន៍ដែលមានជំនាញទាប និងគ្មានជំនាញ ។<br>- ថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៦ បានជួយធ្វើពាក្យបណ្តឹងជូនលោកស្រី កាន់ សុផល អាយុ៤៩ឆ្នាំ រស់ នៅស្រុកកំរៀង ខេត្តបាត់ដំបង ដាក់ជូនក្រសួងការបរទេស ដើម្បីសុំកិច្ចអន្តរាគមន៍ជួយកូនស្រីរបស់ គាត់ឈ្មោះ គឿង សុភាន អាយុ២៣ឆ្នាំ ត្រូវក្រុមហ៊ុន Dragon Cleaning បញ្ជូនទៅធ្វើការនៅប្រទេសម៉ាឡេស៊ី ហើយជួបទុក្ខលំបាកត្រូវម្ចាស់ផ្ទះជេរស្តីគ្មានលោះពេល ។<br>- ថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១៦ បានចូលរួមសិក្ខាសាលាពិគ្រោះយោបល់លើសេចក្តីព្រាងប្រកាសស្តីពី លក្ខខណ្ឌការងារសម្រាប់កម្មករការងារផ្ទះ រៀបចំឡើងដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជា ជីវៈ សហការជាមួយអង្គការ UN-Women នៅសណ្ឋាគារភ្នំពេញ ។<br>- បានស្រាវជ្រាវ និងប្រមូលព័ត៌មានតាមរយៈ តេឡេក្រាម៖<br>• ស្ថានអគ្គកុងស៊ុលកម្ពុជាប្រចាំខេត្តសាកែវ ប្រទេសថៃ បានជួយសម្របសម្រួលដោះលែងពលរដ្ឋ ខ្មែរចំនួន ១៣នាក់ ដែលឆ្លងដែនស្នាក់នៅខុសច្បាប់មុំផ្សាររ៉ុងក្លឿ ឲ្យវិលមកកម្ពុជាវិញ ។<br>• ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសឥណ្ឌូនេស៊ី បានជួយសង្គ្រោះ និងរៀបចំធ្វើមាតុភូមិនិវត្តន៍ ពលករខ្មែរចំនួន ២១នាក់ តាមរយៈអង្គការ IOM ដែលបានរងគ្រោះដោយអំពើរត់ពន្ធមនុស្ស ហើយកំពុងត្រូវបានជាប់ឃុំនៅ ៣កន្លែង (នៅកោះបាលី ១នាក់ នៅកោះRiau ១៨នាក់ និងនៅ កំពង់ផែBelawan ខេត្ត Medan ២នាក់ ។<br>• ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសម៉ាឡេស៊ី បានអន្តរាគមន៍ជួយពលករ-ពលការនី ២នាក់(ពលករនៅខេត្តស្ទឹងត្រែង ទៅធ្វើការជាជាងឈូសឈើដោយខ្លួនឯង និងពលការនីនៅខេត្តកណ្តាល ទៅជាលើកទី២ដោយខ្លួនឯងនៅហាងស្ប៉ាមួយកន្លែង) ។ | ៥លើក | ក្រុមទំនួយកិច្ចការទេសន្តរប្រវេសន៍ |

| | | | | |
|---|---|---|---|---|
| | | - បានបូកសរុបប្រចាំថ្ងៃនូវចំនួនពលករចំណាកស្រុកខុសច្បាប់ ដែលអាជ្ញាធរបរទេសបញ្ជូនមកកម្ពុជាវិញ (ពីថ្ងៃទី ០១-២៤ ខែតុលា ឆ្នាំ២០១៦) ដែលជារបាយការណ៍បូកសរុបប្រចាំថ្ងៃ របស់អគ្គស្នងការ ដ្ឋាននគរបាលជាតិ មានចំនួន ៣៨៣១នាក់ (ស្រី ១២១៥នាក់ កុមារ ៣៧២នាក់) ក្នុងនោះ៖<br>• តាមច្រកប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ៣៦៦០នាក់ (ស្រី ១១៥៨នាក់ កុមារ ៣៤៥នាក់)<br>• តាមច្រកសំពៅលូន ខេត្តពត់ដំបង ១៥៣នាក់ (ស្រី ៥១នាក់ កុមារ ២៥នាក់)<br>តាមច្រកភ្នំដី ខេត្តបាត់ដំបង ១៨នាក់ (ស្រី ០៦នាក់ កុមារ ០២នាក់) ។ | | |
| ២ | ក្រសួងសង្គមកិច្ច | - បានចូលរួមជាសមាជិកគណៈកម្មាធិការកណ្តាល និងអនុគណៈកម្មាធិការរៀបចំទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ ឆ្នាំ២០១៦ នៅមជ្ឈមណ្ឌលសន្និបាត និងពិព័ណ៌កោះពេជ្រ ដើម្បីជាយុទ្ធនាការថ្នាក់ជាតិផ្សព្វផ្សាយ អំពីការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស តាមគ្រប់រូបភាព និងលទ្ធផលផ្លែផ្កាសម្រេចបាន ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។<br>- បានចូលរួមកិច្ចប្រជុំក្រុមការងាររៀបចំតាក់តែងលិខិតបទដ្ឋាន ស្តីពីគោលការណ៍ណែនាំ និងក្រមសិលធម៌ កិច្ចការពារកុមារ ក្រោមអធិបតីភាព ឯកឧត្តម នឹម ថូត រដ្ឋលេខាធិការ និងជាប្រធានក្រុមការងារ ។ | ២លើក | ក្រសួងសង្គមកិច្ច |
| ៣ | បន្ទាយមានជ័យ | - ក្រុមលេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត បានរៀបចំកិច្ចប្រជុំ ស្តីពីការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ប្រចាំត្រីមាសទី៣ ប្រចាំខែកញ្ញា ឆ្នាំ២០១៦ ក្រោមអធិបតីភាពលោកស្រី ប៉ុក ណាឌី អភិបាលរងខេត្ត និងជាប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ ដែលមានសមាសភាពចូលរួមចំនួន៧១នាក់ ស្រីចំនួន១៨នាក់ ។ | ១លើក | គណៈកម្មាធិការ គ.ខ.ប.ជ និងក្រុមលេខាធិការដ្ឋាន |

| | | | | |
|---|---|---|---|---|
| ៤ | បាត់ដំបង | -បានចូលរួមជាវាគ្មិននៅក្នុងទិវាពិគ្រោះយោបល់ ស្តីពីការទប់ស្កាត់ និងលុបបំបាត់ពលកម្មកុមារថ្នាក់ខេត្ត តាម រយៈការអប់រំ និងលើកកម្ពស់ជីវភាពរស់នៅ ធ្វើនៅសណ្ឋាគារខេមរា ខេត្តបាត់ដំបងបានចំនួន០១លើក មានសមាសភាពចូលចំនួន១១៩នាក់ ស្រីចំនួន៦៩នាក់ ។<br>-មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ,មន្ទីរសង្គមកិច្ច ,មន្ទីរសុខាបាល ,មន្ទីរព័ត៌មានខេត្ត ,មន្ទីរទេសចរណ៍ មន្ទីរកសិកម្ម ,មន្ទីរឧស្សាហកម្ម ,មន្ទីរកិច្ចការនារីខេត្ត និងអភិបាលក្រុង/ស្រុកទាំង១៤ ក្នុងខេត្ត ,ស្នងការដ្ឋាននគរបាលខេត្ត ,បញ្ជាការដ្ឋានកងរាជអាវុធខេត្ត បានសហការគ្នារៀបចំកិច្ចប្រជុំផ្សព្វផ្សាយ ស្តីពីការបង្កើត គណៈកម្មាធិការ ការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរ នៃពលកម្មកុមារចំនួន០១លើក សមាសភាពចូលចំនួន៤៩នាក់ស្រីចំនួន៣១នាក់ គាំទ្រថវិកាដោយអង្គការទស្សនៈពិភពលោក នៅសាលាខេត្តបាត់ដំបង ។<br>-បានចូលរួមធ្វើជាវាគ្មិននៅវិទ្យុជាតិចំការចេក FM ៩២.៧0MHz ក្នុងកម្មវិធីសន្ទនាមតិពន្លឺមូលដ្ឋាន ក្រោមប្រធានបទ ស្តីពី "ទីផ្សារការងារ" ។ | ៣លើក | គណៈកម្មាធិការ គ.ខ.ប.ជ និងអង្គភាពមន្ទីរនានា ទាំង ១៤ក្នុងខេត្ត និង អង្គការ ពាក់ព័ន្ធ |
| | ប៉ៃលិន | -គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្រុង/ស្រុក បានចូលរួមប្រជុំជាមួយ គ.ក.ស.ក ឃុំ/សង្កាត់ទាំង៨ ដើម្បីផ្សព្វផ្សាយ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស និងទប់ស្កាត់ការធ្វើចំណាកស្រុកខុសច្បាប់របស់ប្រជាពលរដ្ឋនៅក្នុងខេត្ត ។ | ១លើក | គណៈកម្មាធិការ គ.ខ.ប.ជ ខេត្ត |
| ៥ | កំពង់ធំ | -ក្រុមលេខាធិការដ្ឋាននៃគណៈកម្មាធិការ គ.ខ.ប.ជ ខេត្ត បានរៀបចំការប្រជុំបូកសរុបប្រចាំឆមាសទី១ ឆ្នាំ ២០១៦ និងទិសដៅអនុវត្តបន្ត ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដល់មន្ត្រីលេខាធិការដ្ឋាន ដើម្បី អនុវត្តន៍ផ្សព្វផ្សាយបន្តជូនប្រជាពលរដ្ឋនៅតាមមូលដ្ឋាន ។ | ១លើក | គណៈកម្មាធិការ គ.ខ.ប.ជ ខេត្ត |
| ៦ | កណ្តាល | -លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត បានរៀបចំកិច្ចប្រជុំ ស្តីពីការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សប្រចាំត្រីមាសទី៣ ទិសដៅត្រីមាសទី៤ ឆ្នាំ២០១៦ ដែលមានអ្នកចូលរួមចំនួន៣៥នាក់ ស្រីចំនួន២៥នាក់ នៅសាលប្រជុំសាលាខេត្ត ។<br>-ក្រុមការងារថ្នាក់ស្រុក បានធ្វើកិច្ចប្រជុំប្រចាំខែ ជំរុញឲ្យមន្ត្រីថ្នាក់ស្រុកយកចិត្តទុកដាក់លើស្ថានភាពស្ត្រី និង កុមារ ធ្វើសកម្មភាពផ្សព្វផ្សាយ ស្តីពីការធ្វើចំណាកស្រុកខុសច្បាប់ ដល់ប្រជាពលរដ្ឋយល់ដឹង កុំឲ្យចាញ់បោកឃោសនារបស់ជនខិលខូចមួយចំនួនតូច ដែលមានអ្នកចូលរួមចំនួន៣៥នាក់ ស្រីចំនួន១៩នាក់ ។ | ២លើក | គណៈកម្មាធិការ គ.ខ.ប.ជ និងក្រុមការងារថ្នាក់ ស្រុក |

| | | | | |
|---|---|---|---|---|
| ៧ | តាកែវ | -លោកជំទាវប្រធានក្រុមលេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត បានសហការជាមួយប្រធានក្រុមការងារជំនាញ ធ្វើការប្រជុំដឹកនាំ ស្តីពីសកម្មភាពការងារប្រយុទ្ធប្រឆាំងដោយអំពើជួញដូរមនុស្ស ដែលបានអនុវត្តរយៈពេល១០ខែ ឆ្នាំ២០១៦ មានអ្នកចូលរួមចំនួន០៧នាក់ ស្រីចំនួន០៦នាក់ ។ | ១លើក | គណៈកម្មាធិការ គ.ខ.ប.ជ និងក្រុមលេខាធិការដ្ឋាន |
| ៨ | កំពង់ស្ពឺ | ក្រុមការងារការិយាល័យប្រយុទ្ធប្រឆាំងដោយអំពើជួញដូរមនុស្ស និងការពារអនីតិជននៃស្នងការនគរបាលខេត្ត បានសហការជាមួយការិយាល័យកិច្ចការងារប៉ុស្តិ៍ ធ្វើការប្រជុំដឹ ស្តីពីសកម្មភាពការងារប្រយុទ្ធប្រឆាំងដោយអំពើជួញដូរមនុស្ស បាន៦ប៉ុស្តិ៍ (ប៉ុស្តិ៍ក្រាំងដីវ៉ាយ,ប៉ុស្តិ៍ចំបក់,ប៉ុស្តិ៍ត្រែងត្រយឹង,ប៉ុស្តិ៍អូរ,ប៉ុស្តិ៍តាំងសំរោង និងប៉ុស្តិ៍ ព្រៃវិជ្ជួល) មានកម្លាំងចូលរួមចំនួន៤៨នាក់ ។ | ១លើក | ស្នងការនគរបាលខេត្ត |
| ៩ | ក្រចេះ | -បានរៀបចំកិច្ចប្រជុំដើម្បីត្រួតពិនិត្យក្រុមការងារលេខាធិការដ្ឋាន គ.ជ.ប.ជ និងក្រុមជំនាញអន្តរមន្ទីរ ស្ថាប័នទាំង៦ខេត្ត ស្តីពីការអនុវត្តការងារប្រយុទ្ធប្រឆាំងអំពើជួញដូរ មនុស្សប្រចាំខែតុលា ឆ្នាំ២០១៦ មានសមាសភាពចូលរួមចំនួន៨៩នាក់ ស្រីចំនួន១៩នាក់ ។ | ១លើក | លេខាធិការដ្ឋានខេត្ត |
| ១០ | រតនគិរី | -មន្ទីរកិច្ចការនារីបានចូលរួមសិក្ខាសាលា ស្តីពីការផ្លាស់ប្តូរយោបល់លើផែនការសកម្មភាពទប់ស្កាត់ការរៀបអាពាហ៍ពិពាហ៍ និងការនាមផ្ទៃពោះនៅវ័យជំទង់ ក្រោមអធិបតីភាព លោកជំទាវ ទេស ចាន់សារឿន អនុរដ្ឋលេខាធិការក្រសួងកិច្ចការនារី មានអ្នកចូលរួមចំនួន៧៩នាក់ ស្រីចំនួន៥៨នាក់ ដែលបានសហការជាមួយអង្គការ UNICEF ។ | ១លើក | មន្ទីរកិច្ចការនារីខេត្ត |
| ១១ | កំពង់ចាម | -ក្រុមលេខាធិការដ្ឋាន គ.ខ.ប.ជ ថ្នាក់ក្រុង បានចូលរួមកិច្ចប្រជុំផ្សព្វផ្សាយច្បាប់ដល់ប្រជាពលរដ្ឋ ស្តីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព និងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ។ | ១លើក | លេខាធិការដ្ឋានខេត្ត |

សកម្មភាពសរុបចំនួន៣៨លើក